# ក្រមសីលធម៌សម្រាប់បេក្ខជនប្រឡង

អ្វីៗដែលត្រូវធ្វើ...

- ស្តាប់ អាន និង ធ្វើតាមការណែនាំដែលគេផ្តល់ឲ្យទាំងអស់
- សួរសំណួរ បើសិនជាអ្នកមិនយល់អំពីការណែនាំ
- អានសំណួរនីមួយៗដោយប្រុងប្រយ័ត្ន ជាពិសេស ចម្លើយសម្រាប់ជ្រើសរើស (multiple-choice) ដែលគេសុំឲ្យផ្តល់ «ចម្លើយដែលត្រឹមត្រូវបំផុត»។ ហើយក៏ត្រូវអានសំណួរដែលផ្តល់ ចម្លើយតាមគំនិតរបស់ខ្លួន (open-ended) នឹងការណែនាំអំពីការដែលត្រូវសរសេរ ដោយប្រុងប្រយ័ត្ន មុននឹងឆ្លើយ
- ប្រុងប្រយ័ត្ន នៅពេលដែលអ្នកផ្តល់ចម្លើយ ធ្វើយ៉ាងណា កុំឲ្យរំលង ឬ បំពេញខុសជំពូក
- ធ្វើយ៉ាងណា គូសឲ្យពេញរង្វង់ត្រង់ចម្លើយដែលរើសយក ហើយលុបឲ្យស្អាតត្រង់ចម្លើយដែលអ្នកដូរចិត្ត
- មើលតែក្រដាសប្រឡងរបស់ខ្លួន
- ព្យាយាមឆ្លើយសំណួរនីមួយៗ
- មើលឲ្យច្បាស់ថាអ្នកបានឆ្លើយសំណួរទាំងអស់ដែលនៅក្នុងជំពូកនៃការប្រឡង មុននឹងបិទសៀវភៅប្រឡងរបស់អ្នក ឬ បញ្ជូនចម្លើយចុងក្រោយបង្អស់របស់អ្នកតាមអ៊ិនធ័រណិត
- រាយការណ៍ពីការសង្ស័យនៃការលួចបន្លំទៅ គ្រូ ឬ នាយកសាលា របស់អ្នក

អ្វីៗដែលមិនត្រូវធ្វើ...

- មកកំណត់ត្រាអ្វីទៅពេលប្រឡង
- មានគ្រឿងអេឡិចត្រូនិចអ្វីមួយដែលគេមិនអនុញ្ញាត (ឧ. ទូរស័ព្ទដៃ ទូរស័ព្ទដៃទំនើប (smart phones) ។ល។) នៅពេលប្រឡង។ កត់សម្គាល់ បើសិនជាសមហេតុផល អ្នកអាចមានម៉ាស៊ីនគិតលេខដែលគេអនុញ្ញាតឲ្យ នៅពេលប្រឡង។
- ប្រើម៉ាស៊ីនគិតលេខ ជាមួយសិស្សដទៃ
- ប្រើ រង្វង់សម្រាប់គូសយកចម្លើយដែលនៅក្នុងសៀវភៅចម្លើយ ដើម្បីគូសចោលចម្លើយដែលខុស ឬ គូសយកចម្លើយដែលស្មានថាត្រូវ ដោយគូសលើរង្វង់ច្រើន ហើយលុបចោល។ គូសតែរង្វង់សម្រាប់ចម្លើយដែលត្រូវ ដែលអ្នករើសយកតែប៉ុណ្ណោះ។
- និយាយជាមួយអ្នកដទៃអំពីសំណួរ នៅពេល ឬ ក្រោយពេល ប្រឡង។ (សិស្សអាចពិភាក្សាអំពី វិធីសាស្ត្រ ឬ បញ្ហា នៃការប្រឡងជាមួយ ឪពុកម្តាយ/អាណាព្យាបាល។)
- សរសេរការប្រឡងទុក ដើម្បីចែកសិស្សដទៃទៀតមើល។
- ចេញពីកន្លែងដែលប្រឡងតាមអ៊ិនធ័រណិត រហូតដល់ពេល ប្រឡងចប់ ឬ គេប្រាប់ឲ្យចេញ។
- ប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ដើម្បីផ្សព្វផ្សាយអំពីការប្រឡង និង/ឬ វិញ្ញាសារប្រឡង។